មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សៀវភៅមេរៀនស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ក្នុងឱកាសនៃខែមោទនភាព

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") នឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅមេរៀនស្តីពីនិន្នាការភេទ និងអត្តសញ្ញាណ យេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទក្នុងឱកាសនៃខែមោទកភាព។ កម្មវិធីនេះនឹងប្រារព្ធនៅថ្ងៃអង្គារ ទី៣១ ខែឧសភា ឆ្នាំ២០២២ នៅសណ្ឋាគារសាន់វេ ក្នុងរាជធានីភ្នំពេញ ចាប់ពីម៉ោង ២:០០ រសៀល ដល់ម៉ោង ៥:៣០ ល្ងាច ដោយមានកំណត់អ្នកចូលរួមដែលបានអញ្ជើញប៉ុណ្ណោះ។ កម្មវិធីនេះក៏នឹងផ្សាយផ្ទាល់លើគេហទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក សម្រាប់សាធារណជនទស្សនាផងដែរ។ កម្មវិធីនេះនឹងធ្វើឡើងជាភាសាខ្មែរ ជាមួយនឹងការបកប្រែជាភាសាអង់គ្លេស និងជាភាសាសញ្ញា។

សៀវភៅមេរៀននេះ មានគោលបំណងផ្តល់ជូនអ្នកអានឱ្យយល់ដឹងកាន់តែច្បាស់អំពីសហគមន៍ ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង ("សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា") ព្រមទាំងភាពចម្រុះនៃលក្ខណៈភេទ រួមមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ តាមរយៈមេរៀនទាំង៩ ផ្សេងៗគ្នា។ សៀវភៅមេរៀនស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ សម្រាប់អ្នកចូលរួមនេះអាចស្វែងរកបានជាភាសាខ្មែរតាមរយៈតំណរភ្ជាប់។

បន្ថែមពីការធ្វើបទបង្ហាញអំពីសៀវភៅមេរៀននេះ កម្មវិធីផ្សព្វផ្សាយនេះមានការសំដែងបទចម្រៀងប្រពៃណីរបស់សកម្មជនអ្នកស្រឡាញ់ភេទដូចគ្នា និងការសន្ទនាពិសេសដែលលើកឡើងពីបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា។

**ប្រធានបទ** ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាដាក់ឱ្យប្រើប្រាស់ជាផ្លូវការសៀវភៅមេរៀនស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ក្នុងឱកាសនៃខែមោទកភាព

**ពេលវេលា** ៖ នៅថ្ងៃអង្គារ ទី ៣១ ខែឧសភា ឆ្នាំ ២០២២ ពីម៉ោង ២:០០ រសៀល ដល់ ៥:៣០ ល្ងាច

**ទីកន្លែង** ៖ នៅសណ្ឋាគារសាន់វេ ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ សម្រាប់អ្នកចូលរួមដោយផ្ទាល់គឺមានកំណត់ និងមានការផ្សាយបន្តផ្ទាល់លើទំព័រហ្វេសប៊ុកនៃ ម.ស.ម.ក សម្រាប់សាធារណជនផងដែរ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក លឹម បូរិន អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័ និងលក្ខណៈភេទ នៃ ម.ស.ម.ក តាមរយៈអ៊ីម៉ែលៈ** borin@cchrcambodia.org **ឬ ទូរសព្ទ(៨៥៥)១២៩០៤ ២៦៦។**

**–ចប់–**

## បណ្ណាធិការ

- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) បង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។
- ម.ស.ម.ក គឺជាសមាជិកនៃដៃគូសន្ទនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (“IFEX”) ដែលជាបណ្ដាញសកលនៃសេរីភាពខាងការបញ្ចេញមតិ សម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (“CIVICUS”) និងជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងអំពើទារុណកម្ម(“OMCT”)ជាសមាជិកនៃបណ្ដាញប្រឆាំងទារុណកម្ម អែស អូ អែស និងជាសមាជិក OECD-Watch ផងដែរ។
- គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងនៅឆ្នាំ២០១៣ បានទទួលពានរង្វាន់ទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនងនិងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រីសបេន ប្រទេសអូស្ត្រាលី៕